# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ÷ www.hoksavann.org

ថ្ងៃទី១៣ កុម្ភៈ ២០០៩



ការកើតទុក្ខខ្លះ កើតអំពីអំពើរបស់ខ្លួនឯង ដូចជាបុគ្គលខ្លះមានការលោភលន់ខ្លាំងក៏ប្រព្រឹត្តអំពើទុច្ចរិតលួចប្លន់ពុករលួយ មានទោសៈខ្លាំង ក៏ប្រព្រឹត្តការព្យាបាទលួចសម្លាប់អ្នកដទៃ ក៏ក្តៅក្រហាយផ្លូវចិត្តភ័យខ្លាចរត់គេចខ្លួនខ្លាចរដ្ឋចាប់បានយកទៅកាត់ទោស ឬខ្លាចគេព្យាបាទវិញ ។ ដើម្បីរំលត់ទុក្ខបែបនេះកុំឲ្យកើតមាន ត្រូវកុំប្រព្រឹត្តធ្វើ, បើជ្រុលធ្វើត្រូវឈប់កុំប្រព្រឹត្តធ្វើតទៅទៀត ។ សេចក្តីទុក្ខខ្លះ កើតអំពីបរិយាកាសសង្គមជុំវិញខ្លួនជិះជាន់គ្នារំលោភច្បាប់ប្រជាពលរដ្ឋរស់នៅដោយការភ័យខ្លាច រស់នៅមួយថ្ងៃសំរាប់មួយថ្ងៃ ថ្ងៃនេះរស់នៅគេចផុតពីការគាបសង្កត់គម្រាមកំហែង សំរាប់ថ្ងៃស្អែកមិនដឹងជាយ៉ាងណាទៀតទេ ។ ចិត្តភ័យខ្លាចបានត្រូវរលត់ ពេលណាមនុស្សគ្រប់ឋានៈដែលជាសមាជិករបស់សង្គមនាំគ្នាគោរពច្បាប់ទាំងអស់គ្នា ឲ្យទៅជាប្រទេសនីតិរដ្ឋ ។

ផ្លូវចិត្តនេះ បើកើតទុក្ខខ្លាំងអាចមានឥទ្ធិពលខ្លាំងណាស់ទៅលើផ្លូវកាយ អាចឲ្យកាយដល់នូវសេចក្តីស្លាប់បាន ដូចមានរឿងមួយនិយាយថា មានអ្នកចិត្តវិទូម្នាក់ (Psychologist) មានបំណងចង់ពិសោធមើលកម្លាំងចិត្តរបស់មនុស្ស តើមានឥទ្ធិពលដល់កម្រិតណាដល់រូបរាងកាយ ។ ថ្ងៃមួយអ្នកចិត្តវិទូនោះបានទៅសុំអ្នកទោសអស់ជីវិតម្នាក់ពីនាយកពន្ធនាគារ គេក៏បានអនុញ្ញាតឲ្យតាមពាក្យសុំ ។ អ្នកចិត្តវិទូបាននិយាយប្រាប់អ្នកទោសនោះថា ខ្ញុំនឹងសម្លាប់អ្នកឯងដោយសម្រកឈាម ហើយវាស់មើលដោយចង់ដឹងថា តើឈាមក្នុងខ្លួនមនុស្សមាន

ប៉ុន្មានលីត្រ ។ បើអ្នកយល់ព្រមឲ្យខ្ញុំធ្វើការពិសោធន៍បែបនេះ អ្នកនឹងមានឈ្មោះក្នុងប្រវត្តិវិទ្យាសាស្ត្រពិភពលោក ។ អ្នកទោសនោះគិតថា បើអញមិនស្លាប់នៅពេលនេះទេ ថ្ងៃក្រោយនៅតែស្លាប់ដដែល ព្រោះគេកាត់ទោសប្រហារជីវិតរួចទៅហើយ ក៏នៅស្ងៀមគ្មានឆ្លើយអ្វីឡើយ ។ នៅពេលយប់ អ្នកចិត្តវិទូបានយកអ្នកទោសនោះឲ្យអង្គុយលើកៅអីក្នុងបន្ទប់ងងឹតមួយ ដោយចងអ្នកទោសជាប់នឹងកៅអី ហើយនៅខាងក្រោមជើងបុរសនោះ គេដាក់ធុងមួយឲ្យបុរសនោះដឹងថា ដើម្បីសម្រកឈាម ។ ទន្ទឹមគ្នានឹងអ្នកចិត្តវិទូធ្វើជាអារជើងដោយឡាមឲ្យឈឺបន្តិច នៅក្បែរនោះគេបើកទឹកឲ្យស្រកតក់ៗ ជាស្នូរឲ្យបុរសនោះឮឲ្យសំគាល់ខុសថាឈាមរបស់ខ្លួនស្រក ។ បន្ទាប់ពីប្រើល្បិចបញ្ឆោតនេះចប់សព្វគ្រប់ហើយ អ្នកចិត្តវិទូក៏ដើរចេញពីទីនោះទៅ ។ មួយយប់ទើសភ្លឺ អ្នកទោសនោះចេះតែគិតថា ឈាមអញកំពុងស្រក កាលណាឈាមចេញអស់ពីខ្លួនអញនឹងស្លាប់ ។ ភ្លឺឡើង អ្នកចិត្តវិទូបើកទ្វារចូលទៅមើល ឃើញអ្នកទោសនោះដាច់ខ្យល់ស្លាប់ទៅហើយ ។ តើស្លាប់ដោយហេតុអ្វី ? បើឈាមក្នុងខ្លួនអ្នកទោសនោះគ្មានស្រក់មួយដំណក់សោះ ។ អ្នកចិត្តវិទូអារជើងបុរសនោះគ្រាន់តែជាល្បិចប៉ុណ្ណោះមិនទាំងចេញឈាមផង ឯការឮស្នូរតក់ៗនោះ គឺជាស្នូរទឹកដែលគេបើកពីរ៉ូប៊ីណេឲ្យស្រកនៅបន្ទប់ម្ខាងក្បែរនោះ ។ ឯអ្នកចិត្តវិទូនិយាយប្រាប់អ្នកទោសថា ចង់ដឹងឈាមក្នុងខ្លួនមនុស្សមានប៉ុន្មានលីត្រនោះ គ្រាន់តែជាល្បិចចង់ដឹងកម្លាំងផ្លូវចិត្តប៉ុណ្ណោះ ព្រោះអ្នកវិទ្យាសាស្ត្រដឹងរួចហើយ ឈាមក្នុងខ្លួនមនុស្សមានប៉ុន្មានលីត្រនោះ មិនចាំបាច់សម្លាប់វាល់មើលឡើយ ។ ការពិសោធន៍របស់អ្នកចិត្តវិទូនេះបានលទ្ធផលយ៉ាងច្បាស់ថា ចិត្តមានឥទ្ធិពលខ្លាំងណាស់ទៅលើផ្លូវកាយ ។ យោលតាមន័យរបស់ព្រះពុទ្ធសាសនា អ្នកទោសនោះស្លាប់ដោយសារការភ័យការអស់សង្ឃឹមកម្លាំងផ្លូវចិត្តបានត្រូវធ្លាក់ចុះដែលបណ្តាលឲ្យចលនាបេះដូងទៅជាគាំងឈប់ដើរ មកអំពីមានសញ្ញាសំគាល់ថាឈាមរបស់ខ្លួនស្រក ខ្លួនពិតជាស្លាប់ ។

សេចក្តីស្លាប់ជាការភ័យតក់ស្លុតរបស់មនុស្សសត្វទូទៅ វៀរលែងតែព្រះអរិយបុគ្គលមានព្រះពុទ្ធជាដើម ព្រោះមនុស្សសត្វនៅជាប់ចិត្តនឹងជីវិតរបស់ខ្លួន ។ ដើម្បីបន្ថយនូវការតក់ស្លុតនេះ ព្រះពុទ្ធបានពិចារណានូវមរណានុស្សតិ គឺការ

នឹករឭករឿយៗនូវសេចក្តីស្លាប់ ដោយពិចារណាថា មនុស្សគ្រប់ឋានៈតែងតែមានសេចក្តីស្លាប់នេះគ្រប់គ្នា សូម្បីព្រះពុទ្ធជាម្ចាស់ក៏ព្រះអង្គរំលត់ខន្ធបរិនិព្វាននៅទីបំផុតដែរ ។ ជម្ងឺកើតផ្លូវកាយឲ្យឥទ្ធិពលទៅលើផ្លូវចិត្ត គឺធ្វើឲ្យចិត្តភ័យតក់ស្លុតទៅជាជម្ងឺផ្លូវចិត្តមួយជាន់ទៀត ។ មួយទៀត កាលណាមានសេចក្តីស្លាប់តែងតែមានការព្រាត់ប្រាសគ្នា បើមិនបានពិចារណាតាមផ្លូវធម៌ទេ មនុស្សខ្លះកើតទុក្ខខ្លាំងរហូតដល់វង្វេងស្មារតី ដូចជារឿងនាងកីសាគោតមីនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនា នាងបីកូនដែលស្លាប់ទៅរកគ្រូជួយកូននាងឲ្យរស់ឡើងវិញ ។ ពេលទៅជួបព្រះពុទ្ធ ព្រះអង្គត្រាស់ថា តថាគតចេះប្រោសកូននាងដែលស្លាប់ឲ្យរស់ឡើងវិញបាន ប៉ុន្តែព្រះអង្គដាក់លក្ខខណ្ឌថា ចូរនាងរកគ្រាប់ស្ពៃចំពោះគ្រួសារណាដែលគ្មានមនុស្សស្លាប់មកផ្សំធ្វើថ្នាំ ។ បន្ទាប់ពីស្វែងរក នាងក្រាបទូលព្រះពុទ្ធថា ខ្ញុំព្រះអង្គរកពុំបានទេ ព្រោះគ្រប់គ្រួសារសុទ្ធតែមានមនុស្សស្លាប់ ។ ពេលវេលាដល់ហើយ ទើបព្រះពុទ្ធត្រាស់ថា ម្នាលនាងកីសាគោតមីនាងបានពិសោធខ្លួនឯងហើយ មនុស្សកើតមកតែងតែស្លាប់គ្រប់គ្នា ចំណែកកូននាងក៏ស្ថិតនៅក្នុងចំណោមនេះដែរ គ្មានជនណាជៀសវាងបានឡើយ ។ ចូរនាងដកចិត្តចេញពីកូនដែលស្លាប់នេះ ហើយមានស្មារតីឡើងពិចារណានូវរូបរាងកាយរបស់នាងដែលមានលក្ខណៈមិនខុសគ្នាពីកូនជាទីស្រឡាញ់របស់នាងដែលស្លាប់នោះឡើយ ព្រោះថាសង្ខារ (ខន្ធ៥) ទាំងឡាយដែលកើតឡើងហើ-យ តែងតែវិនាសទៅវិញជាធម្មតា ។ ដោយធម្មរសរបស់ព្រះពុទ្ធ ធ្វើឲ្យនាងមានស្មារតីឡើងវិញ ហើយពិចារណាធម៌តាមការបំភ្លឺរបស់ព្រះអង្គ ធ្វើឲ្យនាងមានការសះស្បើយជម្ងឺផ្លូវចិត្តក្នុងពេលនោះទៅ ។ នេះជាបច្ចេកទេសរបស់ព្រះពុទ្ធក្នុងការសំដែងធម៌ប្រោសនាងកីសាគោតមី ដែលមានទុក្ខខ្លាំងវង្វេងស្មារតីដោយឲ្យនាងពិសោធឃើញការពិតខ្លួនឯង ទើបព្រះអង្គទាញមកបញ្ជាក់ជាក្រោយ ។

(នៅមានត)